**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**<u>កិច្ចព្រមព្រៀង</u>**

**ស្តីអំពី**

**ការពន្យារកិច្ចសន្យាការងារ**

**រវាង**

**ក្រុមហ៊ុន ឌីនហាន អេនធើប្រាយ**

**និង**

**សហជីពរួមទាំងតំណាងកម្មករ នៃក្រុមហ៊ុន ឌីនហាន**

នៅថ្ងៃទី១៥ខែធ្នូឆ្នាំ២០២២ វេលាម៉ោង១៣:០០គត់ នៅការិយាល័យក្រុមហ៊ុន ឌីន ហាន អេនធើប្រាយ មានបើកកិច្ចប្រជុំស្តីពីការដាក់ពន្យារកិច្ចសន្យាការងាររបស់កម្មករនៃក្រុមហ៊ុនឌីនហាន ខាងមុខនេះ៖

**សមាភាពចូលរួមមាន៖**

-តំណាងក្រុមហ៊ុន ឌីន ហាន អេនធើប្រាយ

-តំណាងសហជីពរួមទាំងតំណាងកម្មករនៃក្រុមហ៊ុន ឌីនហាន

ជាកិច្ចចាប់ផ្តើមលោកនាយកក្រុមហ៊ុនបានថ្លែងអំណរអរគុណដល់សមាជិកទាំងអស់ដែលមកចូលរួមប្រជុំ។ បន្ទាប់មកតំណាងខាងក្រុមហ៊ុនបានលើកឡើងថា៖ ដោយសារតែសេដ្ឋកិច្ចពិភពលោកមានការធ្លាក់ចុះ ហើយក្រុមហ៊ុនឌីនហានបានប្រឈមមុខនឹងគ្មានតម្រូវការទីផ្សាររបស់អ្នកប្រើប្រាស់ និងគ្មានការបញ្ជាទិញ ទើបក្រុមហ៊ុនសំរេចចិត្តពន្យារកិច្ចសន្យាការងាររបស់កម្មករទាំងអស់។ដែលមានកម្មករពន្យារសរុប៖ ១១៧៧នាក់ (ស្រី ១០៨៩នាក់ )

**ក្រោយពីបានពិភាក្សាគ្នាយ៉ាងល្អិតល្អន់រួចមកភាគីទាំងអស់បានឯកភាពតាមកាលវិភាគនៃការពន្យារកិច្ចសន្យាការងារនិងប្រាក់ឧបត្ថម្ភដូចខាងក្រោម៖**

- ក្រុមហ៊ុនឌីនហាននិងផ្តល់ប្រាក់ឧបត្ថម្ភចំនួន៣៩ដុល្លារ(សាមសិបប្រាំបួនដុល្លារ)ក្នុងកំឡុងពេលពន្យារកិច្ចសន្យាការងារ គិតពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២២ រហូតដល់ថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៣ ។

មានដូចជាក្រុម៖ **ដេរ វត្ថុធាតុដើម ផ្នែកសំភារៈដេរ ផ្នែកពិនិត្យក្រណាត់ ផ្នែកតុកាត់ ផ្នែកពិនិត្យគុណភាព ផ្នែកអ៊ុត ផ្នែកវេចខ្ចប់ ផ្នែកផ្សារទំនើប ផ្នែកស្តេន ផលិតផលសម្រេច ផ្នែកតំពេង ផ្នែកព្រីន ផ្នែកពិនិត្យវត្ថុធាតុដើម ផ្នែកអ៊ុតស្អិត ផ្នែកជាងម៉ាស៊ីន ផ្នែកគុណភាពវត្ថុធាតុដើម ផ្នែកពិសោធន៍ ផ្នែកកិច្ចការទូទៅ ផ្នែកអនាម័យ ផ្នែកជាងទឹកភ្លើង ផ្នែកគ្រប់គ្រងផលិតផល ផ្នែកដឹកជញ្ជូន ផ្នែកធនធានមនុស្ស ផ្នែកគណនេយ្យ ផ្នែកបរិស្ថាន ផ្នែកព័ត៌មានវិទ្យា។**

ដោយទទួលបានប្រាក់ឧបត្ថម្ភចំនួន៖ ២១ដុល្លារ+៣៩ដុល្លារ=៦០ដុល្លារ (១៦ថ្ងៃ+៣១ថ្ងៃ=៤៧ថ្ងៃ)។

-ក្នុងកំឡុងពេលពន្យារកិច្ចសន្យាការងារ ក្រុមហ៊ុនឌីនហានអេនធើប្រាយ និងបើកប្រាក់ឧបត្ថម្ភ ផ្សេងៗ ជូនកម្មករមុនការពន្យារកិច្ចសន្យាការងារ។

ភាគីទាំងអស់ បានអាននូវខ្លឹមសារ និង យល់ពីអត្ថន័យនៃកិច្ចព្រមព្រៀងយ៉ាងច្បាស់ ហើយបានយល់ព្រមស្ម័គ្រចិត្តផ្តិតមេដៃស្តាំលើកិច្ចព្រមព្រៀងនេះ ដោយគ្មានការបង្ខិតបង្ខំពីជនណាឡើយ។

កិច្ចប្រជុំបានចប់សព្វគ្រប់នៅវេលាម៉ោង១៤:០០ នាថ្ងៃខែឆ្នាំដដែល ក្រោមបរិយាកាសយ៉ាងស្មោះត្រង់ និងស្និទ្ធស្នាលក្រៃលែង។

ថ្ងៃ ពុធ ៦រោច ខែមិគសិរ ឆ្នាំខាល ចត្វាស័ក ពុទ្ធសករាជ ២៥៦៦
ភ្នំពេញ.ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២២

**តំណាងភាគីសហជីព**
**ស្នាមមេដៃស្តាំ**

**តំណាងភាគីក្រុមហ៊ុន**
**ហត្ថលេខា និងត្រា**

ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន ឌីនហានអេនធើប្រាយស៍ DIN HAN ENTERPRISE CO.,LTD KINGDOM OF CAMBODIA

SHIH HSIAO PING